# និន្នាការសេដ្ឋកិច្ច-សង្គម

## Socio-Economic Trends

## ខែតុលា ឆ្នាំ២០២២ / October 2022

**មាតិកា**


| | ទំព័រ |
|---|---|
| **ខ្លឹមសារសង្ខេប/Executive summary** | ១ |
| **១. និន្នាការសេដ្ឋកិច្ចកម្ពុជា/Cambodia economic trends** | ២ |
| ១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់/Consumer price index | ២ |
| ១.២. វិស័យពាណិជ្ជកម្ម/Trade | ៣ |
| ១.៣. វិស័យវិនិយោគឯកជន/Private investment | ៤ |
| ១.៤. វិស័យទេសចរណ៍/Tourism | ៤ |
| ១.៥ វិស័យសំណង់/Construction | ៥ |
| **២. និន្នាការថ្លៃទំនិញសំខាន់ៗ/Commodity prices** | ៥ |
| ២.១. ថ្លៃប្រេង (Crude oil price: Brent, WTI, Dubai) | ៥ |
| ២.២. ថ្លៃអង្ករ (Rice price: 5%, 25%, 100% broken) | ៦ |
| ២.៣. ថ្លៃកៅស៊ូ (Rubber price: TSR20, SGP/MYS) | ៦ |

## **ខ្លឹមសារសង្ខេប / Executive summary**

១. ក្នុងខែតុលា ឆ្នាំ២០២២, សេដ្ឋកិច្ចកម្ពុជា រំពឹងថានឹងបន្តនិន្នាការកើនឡើង ក្នុងឆ្នាំ ២០២២ បន្តគាំទ្រដោយភាពល្អប្រសើរនៃតម្រូវការសកល បើទោះបីរងការប៉ះទង្គិចពីការផ្ទុះឡើងសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែនយ៉ាងណាក្តី ។ ទន្ទឹមនេះ ការសម្រេចបាននូវអត្រាខ្ពស់នៃការចាក់វ៉ាក់សាំង និងការបើកប្រទេសឡើងវិញ បានអនុញ្ញាតឱ្យសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកចាប់ផ្តើមវិលត្រលប់ទៅរកប្រក្រតីភាពវិញ ។ ឈរលើការងើបឡើងវិញនៃសេដ្ឋកិច្ច-សង្គមនាពេលបច្ចុប្បន្ន, ទស្សនវិស័យនៃសេដ្ឋកិច្ចកម្ពុជានៅបន្តមានភាពល្អប្រសើរ ជាពិសេសស្ថានភាពផលិតកម្ម ឆ្លុះបញ្ចាំងតាមរយៈការបន្តកើនឡើងនៃការនាំចេញផលិតផលឧស្សាហកម្ម, ផលិតផលកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ។ បន្ថែមលើនេះ, រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្ត **“ក្របខណ្ឌយុទ្ធសាស្ត្រ និង កម្មវិធីស្តារនិងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ២០២១-២០២៣”** ដែលនឹងជួយស្តារ និងជំរុញវិស័យដែលជាចន្ទល់នៃសេដ្ឋកិច្ចឱ្យកាន់តែប្រសើរឡើង ក្នុងនោះរួមមាន÷ កាត់ដេរ, មិនមែនកាត់ដេរ, ទេសចរណ៍ និង កសិកម្ម។

២. ក្នុងខែតុលា ឆ្នាំ២០២២, ប្រេងសាំងថ្លៃជាមធ្យម ៤ ២៥០៛/ល ធ្លាក់ចុះ ៥,២% និងប្រេងម៉ាស៊ូតថ្លៃជាមធ្យម ៥ ០១៧៛/ល ធ្លាក់ចុះ ៣,២% ធៀបនឹងខែកញ្ញា ឆ្នាំ២០២២ ដោយឡែកថ្លៃនៅលើទីផ្សារអន្តរជាតិ ដែលក្នុងនោះ ប្រេងឆៅ (Brent) ថ្លៃមធ្យម ៩៣,១៣ ដុល្លារ/បារ៉ែល កើនឡើង ៣,៣% និងប្រេងឆៅ (WTI) ថ្លៃមធ្យម ៨៧,២៦ ដុល្លារ/បារ៉ែល កើនឡើង ៤,០% ធៀបនឹងខែកញ្ញា ឆ្នាំ២០២២ ។

៣. ក្នុងរយៈពេល១០ខែ ២០២២, ការនាំចេញទំនិញ (ដកមាស) មានទំហំទឹកប្រាក់ចំនួន ១៧ ០៥៩,៥ លានដុល្លារ បានកើនឡើង ២០,៣% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ។ កំណើននាំចេញ (ដកមាស) ត្រូវបានជំរុញដោយកំណើនវិជ្ជមាន នៃការនាំចេញផលិតផលវាយនភណ្ឌ, កង់, អង្ករ និងទំនិញផ្សេងៗ ។ ទន្ទឹមនេះ ការនាំចូល (ដកមាស) មានទំហំទឹកប្រាក់ចំនួន ២១ ៣៥៧,៧ លានដុល្លារអាមេរិក បានកើនឡើង ១៦% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ។ កំណើននាំចូល (ដកមាស)នេះ បានគាំទ្រដោយកំណើន នៃការនាំចូលក្រណាត់, ប្រេងឥន្ធនៈ, គ្រឿងសំណង់, យានយន្ត និងទំនិញផ្សេងៗ, ទូរទឹកកកនិងទូក្លាសេ្ស, ម៉ាស៊ីនត្រជាក់, គ្រឿងឧបភោគបរិភោគ, ស្ករស, ប៊ីចេង, ប្រេងឆា, ស្រាចំរុះ, ស្រាបៀរ និងផលិតផលផ្សេងៗមួយចំនួនទៀត) ។

៤. ក្នុងរយៈពេល១០ខែ ឆ្នាំ២០២២, ស្ថានភាពភ្ញៀវទេសចរ បានបង្ហាញពីកំណើនខ្ពស់គួរឱ្យកត់សម្គាល់, ជាក់ស្តែងកម្ពុជាទទួលបានភ្ញៀវទេសចរអន្តរជាតិសរុបចំនួន ១ ៥៧៦ ពាន់នាក់ កើនឡើង ៩៩១,១% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ។ កំណើនភ្ញៀវទេសចរអន្តរជាតិនេះត្រូវបានជំរុញដោយការកើនឡើងនៃភ្ញៀវទេសចរថៃ និងភ្ញៀវទេសចរវៀតណាម ។

៥. ក្នុងរយៈពេល១០ខែ ឆ្នាំ២០២២, ចំនួនគម្រោងដែលទទួលបានការអនុញ្ញាតសាងសង់សរុបមាន ៣ ៤០៧ គម្រោង បានធ្លាក់ចុះ ១៩១ គម្រោង និងតម្លៃគម្រោងសរុបមាន ២ ១៩០ លានដុល្លារ បានធ្លាក់ចុះ ៥៧,២% ក្នុងនោះ ប្រភេទសំណង់លំនៅដ្ឋានមាន ៣ ០១៨ គម្រោង (ស្មើនឹង ៨៨,៥៨% នៃសំណើសុំសាងសង់សរុប) បានធ្លាក់ចុះ ៩១ គម្រោង ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ។

៦. ក្នុងរយៈពេល ១០ខែ ឆ្នាំ២០២២, ស្ថានភាពវិនិយោគ បានបង្ហាញពីភាពល្អប្រសើរបន្តិច, ជាក់ស្តែងគម្រោងវិនិយោគឯកជនសរុប[1] មានចំនួន ១១៦ គម្រោង បានកើនឡើង ២៤ គម្រោង, លទ្ធភាពបង្កើតកម្លាំងពលកម្មថ្មីប្រមាណជា ១០៥ ពាន់នាក់ កើនឡើង ៤៣,៣% និង ទុនវិនិយោគសរុប ២ ៧៥៨ លានដុល្លារ កើនឡើង ១៣៦,៦% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន[2] ។

៧. ក្នុងខែតុលា ឆ្នាំ២០២២, សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវាកម្មនៅរាជធានីភ្នំពេញ បានថមយមក ៣,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន ។ កំណើននេះ គឺត្រូវបានជម្រុញដោយអត្រាកំណើនខ្ពស់នៃក្រុមសន្ទស្សន៍ថ្លៃសំខាន់ៗ ដែលមានទំងន់ធំៗ ដូចជាសន្ទស្សន៍ថ្លៃអាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង ៤,៣%, ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត ៣,២% និងជាពិសេសការដឹកជញ្ជូន ១,៥% ។

---

[1] គម្រោងវិនិយោគឯកជនក្រៅតំបន់សេដ្ឋកិច្ចពិសេស ដែលទទួលបានការអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

2 ទិន្នន័យនេះពុំមានបូករួមបញ្ចូលទិន្នន័យរបស់តំបន់សេដ្ឋកិច្ចទេ

# ១. និន្នាការសេដ្ឋកិច្ចកម្ពុជា / Cambodia economic trends

## ១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ / Consumer price index







ប្រភព: វិទ្យាស្ថានជាតិស្ថិតិ

## ១.២. វិស័យពាណិជ្ជកម្ម / Trade



ក្រាហ្វិច ៤÷ កំណើនទឹកប្រាក់នាំចេញ (ដកមាស) ក្នុងរយៈពេល ១០ ខែ ឆ្នាំ២០២២ បានកើនឡើងទាបជាងកំណើនឆ្នាំមុនបន្តិច




ក្រាហ្វិច ៥÷ ទោះជាយ៉ាងនេះក្តី,កំណើននៅតែល្អ ដែលត្រូវបានជំរុញដោយទំនិញសឹងគ្រប់មុខ ជាពិសេស កាត់ដេរ និងកង់ (ដកមាស)




ក្រាហ្វិច ៦÷ ទីផ្សារអាមេរិក, អឺរ៉ុប និង អាស៊ានបានរួមចំណែកធំ ក្នុងទីផ្សារនាំចេញសរុបរបស់កម្ពុជា (ដកមាស)




ក្រាហ្វិច ៧÷ ក្នុងរយៈពេល១០ខែ ឆ្នាំ២០២២ ការនាំចេញ ទៅកាន់ទីផ្សារអាមេរិក អឺរ៉ុប អង់គ្លេស ជប៉ុន និងទីផ្សារ ផ្សេងទៀត ពិសេស កាណាដា, អូស្ត្រាលី និងកូរ៉េខាងត្បូង មានកំណើនល្អ (ដកមាស)




ក្រាហ្វិច ៨÷ ទឹកប្រាក់នាំចូល បានកើនឡើង ធៀបនឹងខែមុន និងធៀបនឹងខែដូចគ្នាឆ្នាំមុន (ដកមាស)





ក្រាហ្វិច ៩៖ ទំហំទឹកប្រាក់នាំចូលទំនិញសំខាន់ៗទាំងអស់ បានកើនឡើង (ដកមាស)

ប្រភព៖ ស្ថិតិទំហំពាណិជ្ជកម្មអន្តរជាតិ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

## ១.៣. ស្ថានភាពវិនិយោគ / Investment



ក្រាហ្វិច ១០៖ ទុនវិនិយោគ



ក្រាហ្វិច ១១៖ ការបង្កើតកម្លាំងពលកម្មថ្មី

ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## ១.៤. វិស័យទេសចរណ៍ /Tourism



ក្រាហ្វិច ១២៖ ចំនួនភ្ញៀវទេសចរអន្តរជាតិសរុបបានបង្ហាញពីការងើបឡើងវិញ

ប្រភព៖ ក្រសួងទេសចរណ៍

## ១.៥. ស្ថានភាពសំណង់ / Construction

ក្រាហ្វិចទី ១៣÷ ចំនួនសំណើសុំសាងសង់សរុបនៅនិងជាតំលៃ




ប្រភព÷ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ២. និន្នាការថ្លៃទំនិញសំខាន់ៗ / Commodity prices

### ២.១. ថ្លៃប្រេង÷

ក្រាហ្វិច ១៤÷ និន្នាការថ្លៃប្រេងសាំង និងប្រេងម៉ាស៊ូតលើទីផ្សារកម្ពុជា




ប្រភព÷ ក្រសួងពាណិជ្ជកម្ម

ក្រាហ្វិច ១៥ ÷និន្នាការថ្លៃប្រេងសាំងស្តង់ដារលើទីផ្សារអន្តរជាតិ




ប្រភព÷ ធនាគារពិភពលោក (Pink Sheet)

## ២.២. ថ្លៃអង្ករ៖




ប្រភព៖ World Bank (Pink Sheet)

**************

**<u>កំណត់សម្គាល់</u>**

កៅស៊ូ÷

- កៅស៊ូ TSR20: ឬហៅថាកៅស៊ូស្តង់ដារលេខ២០ រួមមានកៅស៊ូ SIR20, SMR20 និង STR20 គឺសំដៅលើកៅស៊ូធម្មជាតិដែលមានសារធាតុផ្សេងៗទៀត២០% ។ កៅស៊ូធម្មជាតិមានច្រើនប្រភេទ ក្នុងនោះកៅស៊ូដែលមានតម្រូវការប្រើប្រាស់ច្រើនជាងគេគឺកៅស៊ូស្តង់ដារ (កៅស៊ូដុំ) និងកៅស៊ូបន្ទះ។ កៅស៊ូ TSR20 ជាប្រភេទកៅស៊ូដែលបានកែច្នៃក្នុងកម្រិតខ្ពស់ ប្រើប្រាស់សម្រាប់ ផលិតកម្មកង់ឡាន បំពង់ទីបជ័រ កម្រាលជ័រ ស្បែកជើង និងអាវភ្លៀងជាដើម។ កៅស៊ូប្រភេទនេះមានកម្រិតស្អិតទាប ហើយងាយលាយបញ្ចូល ជាមួយសារធាតុដទៃ ដែលធ្វើឱ្យផលិតផលផលិតចេញពីកៅស៊ូនេះមានភាពរឹងមាំធន់ និងមិនងាយសឹករិចរិល។ ប្រទេសសំខាន់ៗដែលផលិត កៅស៊ូប្រភេទនេះគឺម៉ាឡេស៊ី ថៃ ឥណ្ឌូណេស៊ី វៀតណាម និងចិន។
- កៅស៊ូ RSS (Ribbed Smoked Sheets) បែងចែកជា៦ប្រភេទគឺ ប្រភេទលេខ 1, 2, 3, 4, 5 និងប្រភេទពិសេស មានពណ៌លឿង និងវេចខ្ចប់ជាបន្ទះ ។ កៅស៊ូប្រភេទ RSS3 ច្រើនផលិតនៅប្រទេសថៃ ឥណ្ឌា និងឥណ្ឌូណេស៊ី ប្រើប្រាស់ជាវត្ថុធាតុដើម សម្រាប់ផលិតសំបកកង់រថយន្ត បំពង់ទីបជ័រ និងស្បែកជើង ។ កៅស៊ូប្រភេទនេះប្រើប្រាស់ក្នុងឧស្សាហកម្មផលិតសំបកកង់ រថយន្ត និងដែលជាធាតុផ្សំលើស 50% នៃផលិតផល ។

ប្រេងឆៅ÷

ប្រេងឆៅ Brent, WTI និង Dubai ជាប្រភេទប្រេងឆៅធុនស្រាល (Light Crude Oil) ដែលមានការទិញលក់ច្រើនជាងគេ និងជាថ្លៃមូលដ្ឋានក្នុងការទិញលក់កិច្ចសន្យាអនាគត (Future Contract) ។ ប្រេងឆៅលើទីផ្សារអន្តរជាតិមានលក្ខណៈខុសគ្នា ទៅតាមប្រភេទដូចជា÷ ប្រភេទប្រេង Brent ច្រើនផលិតនៅតំបន់សមុទ្រអាត្លង់ទិចខាងជើង, ប្រភេទប្រេងរបស់អាមេរិក WTI (West Texas Intermediate) និងប្រភេទប្រេងរបស់អារ៉ាប់ប៊ីសាអ៊ូឌីត Dubai ។ ប្រភេទប្រេងឆៅទាំងបីមានលក្ខណៈ ខុសគ្នាទៅតាមកម្រិតភាពស្រាល ហើយប្រភេទប្រេងឆៅដែលមានភាពស្រាលជាងគេអាចចម្រាញ់ជាប្រេងឥន្ធនៈបានច្រើន។ API Gravity ត្រូវបានគេប្រើប្រាស់ វាស់វែងភាពស្រាលនៃប្រភេទប្រេងឆៅនីមួយៗ ។ ប្រភេទប្រេងដែលមានកម្រិត API Gravity កាន់តែខ្ពស់គឺជាប្រភេទប្រេងដែលកាន់តែស្រាល និងអាចចម្រាញ់ជាប្រេងឥន្ធនៈបានច្រើន ។

- WTI 40° API
- Brent 38° API
- Dubai 32° API

*រៀបចំដោយ*

*នាយកដ្ឋានស្ថិតិនិងវិភាគសេដ្ឋកិច្ច*

*អគ្គនាយកដ្ឋានគោលនយោបាយ*

*ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

*ព័ត៌មានផ្សេងៗ សូមទាក់ទងក្រុមការងារ:០*

*ទូរស័ព្ទលេខ÷ ០១៧ ៣៦៦ ៥៥៣, ០៧៧ ៨៨ ៩៩ ៩២*

*ម៉ោងធ្វើការ÷ ៨:០០ ដល់ ១២:០០ព្រឹក និង ២:០០ ដល់ ៥:០០រសៀល*